**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួល ឯកឧត្តម អាំផៃ គីនដាវង់ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នាព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យឯកឧត្តម **ឯកឧត្តម អាំផៃ គីនដាវង់** (Amphay KINDAVONG) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែល **ឯកឧត្តម** បានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរចំពោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ដែលបានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា ប្រកបដោយជោគជ័យ និងបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម** ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ និងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរ ក្នុងស្មារតីនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង ដើម្បីផលប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា និងឡាវ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ផងដែរថា នៅក្នុងអាណត្តិបេសកកម្មការទូតរបស់ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ប្រទេសទាំងពីរ បានរៀបចំការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់នៃប្រទេសទាំងពីរ និងទទួលបានសមិទ្ធផលប្រកបដោយផ្លែផ្កា។

ជាកិច្ចឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណជាពិសេសជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានទទួលជួបសវនាការរបស់ **ឯកឧត្តម** នៅក្នុងពេលវេលាដ៏មមាញឹកនេះ និងចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អ និងភាពស្និទ្ធស្នាលរបស់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាមូលដ្ឋានដ៏យ៉ាងសំខាន់ក្នុងការរួមចំណែកធ្វើឱ្យបេសកកម្មការទូតរបស់ **ឯកឧត្តម** នៅព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យ។

**ឯកឧត្តម** បានគូសបញ្ជាក់ថា ក្នុងអាណត្តិបេសកម្មការទូត **ឯកឧត្តម** បានសង្កេតឃើញថាកម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅលើគ្រប់វិស័យ ហើយប្រសិនបើគ្មានវិបត្តិជំងឺកូវីដ-១៩ នោះទេកម្ពុជាពិតមានសន្ទុះនៃការរីកចម្រើនយ៉ាងខ្លាំងជាងនេះ ជាក់ជាមិនខាន។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** ក៏បានថ្លែងកោតសរសើរថា កម្ពុជាជាប្រទេសដ៏ល្អសម្រាប់ការស្នាក់នៅ និងបំពេញការងារការទូត ដោយម្យ៉ាង

ប្រជាជនកម្ពុជាមានសមានចិត្តល្អ និងរួសរាយរាក់ទាក់ និងម្យ៉ាងទៀតមានការគាំទ្រនិងសហការល្អពីថ្នាក់ដឹកនាំកម្ពុជាគ្រប់ជាន់ថ្នាក់។ **ឯកឧត្តម** ពិតជាមានក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលមានឱកាសបានបំពេញបេសកម្មការទូត និងរស់នៅកម្ពុជាជាងបីឆ្នាំនេះ។

ឆ្លៀតក្នុងឱកាសនេះដែរ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់ការផ្តល់ជំនួយដ៏ថ្លៃថ្លាជូន ប្រទេសឡាវ រួមមាន ថវិកា វ៉ាក់សាំងកូវីដ-១៩ សម្ភារៈបរិក្ខារវេជ្ជសាស្រ្តជាបន្តបន្ទាប់ ជាពិសេសនៅក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ ផនខាំ វីផាវ៉ាន់** នាពេលថ្មីៗនេះ។

ភាគីទាំងពីរក៏បានលើកឡើងផងដែរ អំពីបញ្ហាអនុតំបន់ តំបន់ និងអន្តរជាតិ ដែលជាចំណាប់អារម្មណ៍រួម។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណឡាវ ចំពោះការគាំទ្រដល់កម្ពុជា ក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ប្រកបដោយជោគជ័យកាលពីពេលថ្មីនេះ និងចំពោះតួនាទីរបស់កម្ពុជា ជាប្រធានអាស៊ាន នៅឆ្នាំ២០២២ ៕